## សម្រាប់ការថែទាំផ្នែកវេជ្ជសាស្ត្រជាបន្ទាន់

**ហៅទូរសព្ទទៅ 000** ឬទៅកាន់ផ្នែកសង្គ្រោះបន្ទាន់ដែលនៅជិតបំផុតរបស់អ្នក។

## ការបកប្រែភាសាសរសេរ និងផ្ទាល់មាត់

សូមហៅទូរសព្ទទៅលេខ 131 450 និងស្នើសុំហៅទៅលេខ 1800 360 000។ នេះជាសេវាដោយឥតគិតថ្លៃ។

## ការបាត់បង់ក្នុងការនិយាយ ឬការស្តាប់ឮ

យើងទទួលយក TTY និងការហៅទូរសព្ទតាមរយៈសេវាកម្មជាតិផ្នែកប្រាស្រ័យទាក់ទងជាមួយជនពិការ (National Relay Service) – តុជំនួយលេខ 1800 555 660

## ចែករំលែកមតិកែលម្អរបស់អ្នក

យើងផ្តល់គុណតម្លៃដល់មតិកែលម្អរបស់អ្នក
អ៊ីមែល – advice@pcas.org.au
ទូរសព្ទ – 1800 360 000

**www.pcas.org.au**

# 1800 360 000

7 ព្រឹក–10 ល្ងាច ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍

សេវាផ្តល់ដំបូន្មានការថែទាំដើម្បីបំបាត់ការឈឺចាប់បណ្តោះអាសន្នរដ្ឋវិចថូរៀ ត្រូវបានផ្តល់មូលនិធិដោយក្រសួងសុខាភិបាល បានធ្វើប្រតិបត្តិការដោយមន្ទីរពេទ្យ ហើយបានគាំទ្រដោយរដ្ឋាភិបាលរដ្ឋវិចថូរៀ។

ដើម្បីទទួលការបោះពុម្ពផ្សាយនេះជាទម្រង់អាចចូលប្រើបាន សូមហៅទូរសព្ទទៅលេខ 1800 360 000 ដោយប្រើសេវាកម្មជាតិផ្នែកប្រាស្រ័យទាក់ទងជាមួយជនពិការ (National Relay Service) លេខ 13 36 77 ប្រសិនបើត្រូវការ ឬអ៊ីមែល <advice@pcas.org.au>

បានអនុញ្ញាត និងបានបោះពុម្ពផ្សាយដោយរដ្ឋាភិបាលរដ្ឋវិចថូរៀ (Victorian Government), 1 Treasury Place, Melbourne។

© រដ្ឋវិចថូរៀ ខែធ្នូ ឆ្នាំ 2024 (2006731)



# រដ្ឋវិចថូរៀ ការថែទាំដើម្បីបំបាត់ការឈឺចាប់បណ្តោះអាសន្ន

## សេវាផ្តល់ដំបូន្មាន

# 1800 360 000

7 ព្រឹក–10 ល្ងាច ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍

## សម្រាប់មនុស្សគ្រប់រូប នៅគ្រប់ទីកន្លែង នៅរដ្ឋវិចថូរៀ

VICTORIA State Government

គោលបំណងនៃការថែទាំដើម្បីបំបាត់ការឈឺចាប់ជាបណ្ដោះអាសន្នគឺដើម្បីកែលម្អគុណភាពជីវិតសម្រាប់មនុស្ស និងគ្រួសារនានាដែលកំពុងរស់នៅមានជំងឺកំណត់ជីវិត។

## សេវាផ្ដល់ដំបូន្មាននេះគឺសម្រាប់មនុស្សគ្រប់រូបនៅរដ្ឋវិចថូរៀ។

### តើអ្នកកំពុងរស់នៅមានជំងឺកំណត់ជីវិតឬ?

### តើអ្នកជាអ្នកថែទាំ សមាជិកគ្រួសារ មិត្តភ័ក្តិ ឬអ្នកជិតខាងរបស់អ្នកណាម្នាក់ដែលកំពុងរស់នៅមានជំងឺកំណត់ជីវិតទេ?

យើងអាចជួយជាមួយនឹងសំណួរនានាដូចជា៖

- តើការថែទាំដើម្បីបំបាត់ការឈឺចាប់ជាបណ្ដោះអាសន្នជួយមនុស្សដែលខ្ញុំគាំទ្រយ៉ាងដូចម្ដេច?
- តើខ្ញុំអាចស្វែងរកព័ត៌មានអំពីការធ្វើជាអ្នកថែទាំនៅកន្លែងណា?
- តើខ្ញុំរកសេវាផ្ដល់ការថែទាំដើម្បីបំបាត់ការឈឺចាប់បណ្ដោះអាសន្នដែលត្រឹមត្រូវបានយ៉ាងដូចម្ដេច?
- តើអ្វីខ្លះដែលខ្ញុំអាចធ្វើការសម្រាលដល់ការឈឺចាប់របស់ខ្ញុំ? ការចង្អោររបស់ខ្ញុំ? ភាពដង្ហក់របស់ខ្ញុំ?
- តើខ្ញុំត្រូវការគិតអំពីអ្វីខ្លះ និងរៀបចំផែនការអ្វីខ្លះ?
- តើខ្ញុំនិយាយជាមួយអ្នកផ្ដល់សេវាថែទាំសុខភាពទាក់ទងនឹងការថែទាំដើម្បីបំបាត់ការឈឺចាប់ជាបណ្ដោះអាសន្នយ៉ាងដូចម្ដេច?

### តើអ្នកជាវេជ្ជបណ្ឌិត គិលានុប្បដ្ឋាន ឬអ្នកផ្ដល់សេវាថែទាំសុខភាពដទៃទៀតកំពុងថែទាំនរណាម្នាក់ដែលជំងឺកំណត់ជីវិតទេ?

គិលានុប្បដ្ឋាន ឬវេជ្ជបណ្ឌិតឯកទេសក្នុងការថែទាំដើម្បីបំបាត់ការឈឺចាប់ជាបណ្ដោះអាសន្នអាចផ្ដល់ជំនួយជាមួយនឹងបញ្ហានានាដូចជា៖

- ការគ្រប់គ្រងរោគសញ្ញា
- ការចេញវេជ្ជបញ្ជា
- ការបង្វែរឱសថនានាពីឱសថពិសាតាមមាត់ទៅជាឱសថចាក់
- ការចាក់បញ្ចូលក្រោមស្បែកជាបន្ត (បំពង់ស៊ីរ៉ាំងចាក់)
- ការធ្វើសេចក្ដីសម្រេចចិត្ត និងការធ្វើឱ្យវិវត្តន៍ទៅមុខក្នុងការរៀបចំផែនការថែទាំ។

យើងមិនអាចផ្ដល់វេជ្ជបញ្ជា ការបញ្ជូនបន្ត ការចូលប្រើប្រាស់កំណត់ត្រាផ្នែកវេជ្ជសាស្ត្រ ឬជំនួសការថែទាំរបស់អ្នកផ្ដល់សេវាថែទាំសុខភាពនៅតាមតំបន់បានទេ។

**1800 360 000**

7 ព្រឹក–10 ល្ងាច ប្រាំពីរថ្ងៃក្នុងមួយសប្ដាហ៍

ឥតគិតថ្លៃ និងមានលក្ខណៈសម្ងាត់

**www.pcas.org.au**